# ៩. សេចក្ដីផ្ដើម

៩.១ ផ្នែកនេះចែងពីគោលនយោបាយមួយសំរាប់អភិវឌ្ឍ **កម្មវិធីសិក្សាមធ្យមសិក្សាទុតិយភូមិ** នៅប្រទេសកម្ពុជា ក្នុងបរិបទដែលមានក្នុង **ផែនការជាតិអប់រំសំរាប់ទាំងអស់គ្នាឆ្នាំ ២០០៣. ២០១៥**។ ផ្នែកនេះពណ៌នាពី គោលបំនង និងរចនាសម្ព័ន្ធនៃកម្មវិធីសិក្សា ពីថ្នាក់ទី ១០ដល់ទី ១២ ព្រមទាំងម៉ោងបង្រៀន។

៩.២ ខ្លឹមសារលំអិតនៃកម្មវិធីសិក្សានឹងត្រូវចែងនៅក្នុងឯកសារថ្មី **កម្មវិធីសិក្សាមធ្យមសិក្សទុតិយភូមិ** ។

៩.៣ គោលបំនងនៃកម្មវិធីសិក្សា **មធ្យមសិក្សាទុតិយភូមិ** មិនគ្រាន់តែពង្រឹង និងពង្រីកចំនេះដឹងដែលសិស្សទទួលបានពីកម្មវិធីសិក្សាអប់រំមូលដ្ឋានប៉ុណ្ណោះទេ គឺថែមទាំងផ្ដល់ការសិក្សាបែបតំរង់ទិស ដើម្បីមានសមត្ថភាពអាចបន្តការសិក្សានៅឧត្តមសិក្សា ឬ សិក្សាឯកទេស ឬ ចូលរួមក្នុងជីវភាពសង្គម ដោយធានាថាសិស្សនឹងទទួលបាន :

- ការចេះដឹងកាន់តែខ្ពស់ផ្នែកអក្សរសាស្ត្រខ្មែរ និង គណិតវិទ្យា
- ការស្គាល់អត្តសញ្ញាណជាតិកាន់តែច្បាស់
- ការអភិវឌ្ឍការយល់ដឹងកាន់តែខ្លាំងពី សីលធម៌រស់នៅ និង ការទទួលខុសត្រូវរបស់ពលរដ្ឋចំពោះប្រទេស
- បំនិនជីវិតប្រចាំថ្ងៃ ចាំបាច់សំរាប់ការចូលរួមក្នុងជីវភាពសហគមន៍មូលដ្ឋាន និងក្នុងសង្គមកម្ពុជា
- ការយល់ដឹងកាន់តែទូលំទូលាយពីពិភពលោក និង គោលការណ៍វិទ្យាសាស្ត្រ
- សមត្ថភាពកាន់តែខ្ពស់ក្នុងទំនាក់ទំនងជាភាសាបរទេស ។

៩.៤ **កម្មវិធីសិក្សាជាតិ** នៅថ្នាក់ទី១០-១២ មានមុខវិជ្ជាសិក្សា និង បំនែងចែកម៉ោងសិក្សាតាមមុខវិជ្ជានីមួយៗ ដែលមួយម៉ោងសិក្សាមានរយៈពេល ៥០ នាទី ។